## I. គោលបំណងនៃការស្ទាបស្ទង់មតិ:

ក្នុងគោលបំណង ដើម្បីរួមចំណែកចំពោះការផ្សះផ្សាជាតិដ៏ពិតប្រាកដ វិទ្យាស្ថានបានធ្វើការស្ទង់មតិមួយទៅលើបទពិសោធន៍របស់ប្រជាពលរដ្ឋខ្មែរក្នុងរបបខ្មែរក្រហម និងក្តីរំពឹងរបស់ពួកគាត់ទៅលើសាលាជំរះក្តីកាត់ទោសខ្មែរក្រហម ដែលនឹងរៀបចំឡើងនៅពេលខាងមុខនេះ ដោយមាន**គោលបំណងពីរយ៉ាង:**

១. ដើម្បីធ្វើឱ្យមន្ត្រីកម្មវិធីវ័យក្មេងប្រាំមួយនាក់របស់វិទ្យាស្ថាន ឱ្យបានដឹងច្បាស់អំពីបទពិសោធន៍ អារម្មណ៍ និងតំរូវការរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។
ដូចគ្នានឹងប្រជាពលរដ្ឋជាង៥០%ទៀតដែរ យុវជនទាំងប្រាំមួយនាក់នេះកើតក្រោយឆ្នាំ ១៩៧៩ ហើយដឹងតិចតួចបំផុតអំពីប្រវត្តិសាស្ត្រនាពេលថ្មីៗនៃប្រទេសរបស់ពួកគាត់ ។ តាមរយៈការជួបសម្ភាសផ្ទាល់ជាមួយសមាជិកនៃជំនាន់មុន បានផ្តល់ឱកាសឱ្យពួកគេស្វែងយល់កាន់តែច្បាស់អំពីអ្វីដែលបានកើតឡើងក្នុងកំឡុងឆ្នាំ ១៩៧៥-១៩៧៩ ហើយអាចធ្វើឱ្យពួកគេកសាងទំនាក់ទំនងជាការបោះជំហានដំបូងឆ្ពោះទៅរកការផ្សះផ្សាគ្នា ។ ក្នុងចំណោមមន្ត្រីកម្មវិធីទាំង៦រូបនេះ មាន ៥រូប ជានិស្សិតបញ្ចប់បរិញ្ញាប័ត្រនីតិសាស្ត្រ និងមួយរូបជានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ហើយដែលត្រូវបានបណ្តុះបណ្តាល ដើម្បីឱ្យក្លាយជាអ្នកឃ្លាំមើលការកាត់ទោសខ្មែរក្រហម ដែលនឹងប្រព្រឹត្តទៅ នាពេលខាងមុខនេះ ។

២. ធ្វើឱ្យយើងបានដឹងច្បាស់អំពីក្តីសង្ឃឹម និងក្តីរំពឹងទុករបស់អ្នករួចផុតពីសេចក្តីស្លាប់ទៅលើការជំនុំជំរះពួក-ខ្មែរក្រហម នៅពេលខាងមុខ ដើម្បីរៀបចំគំរោងចុះផ្សព្វផ្សាយមួយអំពីសាលាជំរះក្តីនេះ សំដៅបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការជំនុំជំរះ និងការពង្រឹងនីតិរដ្ឋ ។

ការស្ទង់មតិនេះមិនបានធ្វើឡើងដោយអ្នកជំនាញក្នុងការធ្វើសម្ភាសទេ ហើយក៏មិនបានប្រើប្រាស់វិធីសាស្ត្រ ជាលក្ខណៈវិទ្យាសាស្ត្រដែលមានវិជ្ជាជីវៈឯកទេសដែរ ។ អាស្រ័យហេតុនេះ ការស្ទាបស្ទង់មតិនេះ និងលទ្ធផលរបស់វា **មិនគួរចាត់ទុកជា តំណាងឱ្យប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសទេ** ប៉ុន្តែគួរត្រូវបានចាត់ទុកត្រឹមតែជា មតិរបស់អ្នកផ្តល់ការសម្ភាសន៍តែប៉ុណ្ណោះ ។

## II. ការចុះធ្វើការស្ទាបស្ទង់មតិ

**ការសម្ភាសន៍ចំនួន ៥៣៦ បានធ្វើឡើងនៅក្នុង រាជធានីភ្នំពេញ និងខេត្តចំនួន ១០ នៅចន្លោះពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០៤** ។ ខេត្តទាំងនេះរួមមាន: